# អុបោសថកាលសង្ខេប

អុបោសថកម្មរបស់អុបាសកអុបាសិកា បើពោលដោយកាលដែលជាទីរក្សានូវអុបោសថសីលនោះមាន ពីរប្រការគឺ

១ - បកតិអុបោសថ អុបោសថកម្មដែលប្រព្រឹត្តទៅដោយប្រក្រតី គឺអុបោសថកម្មដែលអ្នកប្រាជ្ញទាំងឡាយលោកធ្វើមកហើយអំពីដើម។

២ - បដិជាគរអុបោសថ អុបោសថកម្មនៃបុគ្គលភ្ញាក់រលឹករឿយៗ គឺរលឹកដល់អុបោសថសីលដែលជាកុសលគឺខ្លួនត្រូវសន្សំ។

កាលនៃបកតិអុបោសថ ក្នុង១ខែមាន៨ថ្ងៃគឺថ្ងៃចំណែកខាងសុក្កបក្ខខ្នើត ៤ថ្ងៃ និងកាលបក្ខរនោច ៤ថ្ងៃគឺ ត្រូវត្រង់

- ៥ កើត៨កើត ១៤កើត ១៥កើត
- ៥ រោច ៨រោច ១៤រោច ១៥រោច

បើខែដាច់ខ្លះត្រូវត្រង់១៤រោច អុបោសថថ្ងៃ១៤រោច ថយមក១៣រោជវិញ កាលនៃបដិជាគរអុបោសថ ក្នុង១ខែមាន១១ថ្ងៃ គឺត្រូវត្រង់

- ៤កើត៦កើត ៧កើត ៩កើត ១៣កើត
- ១រោច៤រោច ៦រោច ៧រោច ៩រោច ១៣រោច

ថ្ងៃអែទៀតក្រៅអំពីបកតិអុបោសថ និងបដិជាគរអុបោសថនោះ មាន១១ថ្ងៃគឺ

- ១, ២, ៣,១០, ១១, ១២ កើត
- ១, ២, ៣, ១០, ១១, ១២ រោច

បើខែខ្លះ មាន១០ថ្ងៃត្រូវត្រង់ថ្ងៃ១២រោច ទុកជាថ្ងៃបដិជាគរអុបោសថ ថ្ងៃទាំង ១១ រឺ១០នេះ មិនមែនជាកាល នៃអុបោសថណាមួយឡើយ គ្រប់ៗខែទាំងអស់។ នឹងអធិប្បាយពីកិច្ចដែល នឹងធ្វើនូវអុបោសថកម្ម គឺបកតិអុបោសថ និងបដិជាគរអុបោសថ ជាសេចក្តីខ្លីៗបន្តិច គ្រាន់ជាទីចំណាំរបស់អុបាសកអុបាសិកាទាំងឡាយក្នុងព្រះពុទ្ធសាសនា អែបកតិអុបោសថកម្មនោះ គឺអុបោសថសីលដែលអុបាសកអុបាសិកាត្រូវទទួលសមាទានកាន់រក្សានូវសិក្ខាបទទាំង៨ ក្នុងថ្ងៃបកតិអុបោសថកាល កំណត់ត្រឹមតែ១ថ្ងៃ១យប់តាមលំដាប់កាលនៃបកតិអុបោសថនោះ អែបដិជាគរអុបោសថនោះ គឺអុបោសថសីលដែលអុបាសកអុបាសិកា ត្រូវដុសខាត់សំអាតចិត្តនឹករលឹកដល់សិក្ខាបទទាំង៨ ដែលជាអង្គនៃអុបោសថសីល តែអុបាសកអុបាសិកាមិនត្រូវសមាទានឡើយ គ្រាន់តែបណ្តោះចិត្តអោយឃ្លាតឆ្ងាយអំពីកាមគុណ៥ ហើយបំរុងចាំដំណើរ នៃបកតិអុបោសថសីល គឺគ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង៨ មានបាណាតិបាតាជាដើម ដូចជារក្សានូវអុបោសថសីលក្នុងថ្ងៃបកតិអុបោសថនោះដែរ ប្លែកគ្នាគ្រាន់តែមិនសមាទាន និងសមាទានប៉ុណ្ណោះ គឺថាបដិជាគរអុបោសថនោះមិនមានសមាទានទេ គ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទដែលត្រូវវៀរអស់ថ្ងៃ១យប់១ជាកំណត់ អែបកតិអុបោសថសីលនោះ ត្រូវសមាទានទទួលកាន់យកនូវសិក្ខាបទទាំង ៨ រក្សាអស់ថ្ងៃ១ និងយប់១ដែរ វេលាដល់គ្រប់កំណត់កាល បកតិអុបោសថសីល ថយទៅហើយ ត្រូវតាំងចិត្តទៅជូនដំណើរនៃអុបោសថសីលនោះអស់ថ្ងៃ១ យប់១ ទៀត គឺតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង៨ តែមិនបាច់ទទួលសមាទានទេ គឺគ្រាន់តែ ញ៉ាំងចិត្តអោយប្រព្រឹត្តទៅតាមបកតិអុបោសថសីល ដែលខ្លួនទទួលសមាទានអំពីថ្ងៃម្សិលប៉ុណ្ណោះអែង។

អែបកតិអុបោសថកាលនោះកាលព្រះសម្មាសម្ពុទ្ធគង់ព្រះធរមាននៅឡើយ ព្រះអង្គសំដែងទុកថា ក្នុង១ខែមាន៦ថ្ងៃ ខាងខ្នើត៣ថ្ងៃ ខាងរនោច៣ថ្ងៃ គឺ

- ថ្ងៃ៨កើត ៨រោច ហៅថាអដ្ឋមីអុបោសថ
- ថ្ងៃ១៤កើត ១៤រោច ហៅថាចាតុទ្ទសីលអុបោសថ
- ថ្ងៃ១៥កើត ១៥រោច ហៅថាបណ្ណរសីអុបោសថ

បើខែខ្លះត្រង់ថ្ងៃ១៥រោចត្រូវថយចុះមកថ្ងៃ១៤រោចវិញ លុះដល់ព្រះអង្គចូលបរិនិព្វានទៅបាន៣ខែ ព្រះ

អរហន្តទាំងឡាយ៥០០ ព្រះអង្គ មានព្រះមហាកស្សបត្ថេរជាដើម លោកប្រជុំគ្នាធ្វើបឋមសង្គាយនាផ្ទៀង ផ្ទាត់ធម៌វិន័យ លោកយល់ឃើញថា នៅវេលាថ្ងៃខាងដើមនោះពេកណាស់ ទើបលោកលើកយកថ្ងៃ៥ កើត ៥រោចមកកំណត់ទុកជាថ្ងៃបកតិអុបោសថផង រួមគ្នាជាបកតិអុបោសថកាល ក្នុង១ខែៗមាន៨ ថ្ងៃ ព្រោះត្រង់ថ្ងៃ៥កើត៥រោចជាថ្ងៃអុបោសថកាលដែរ ហៅថាបញ្ចមីអុបោសថ។

ចប់អុបោសថដោយសង្ខេបតែប៉ុណ្ណោះ។